**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខៈ ៣៩៣៨ ប្រក

# ប្រកាស
## ស្តីពី
## ការប្រើប្រាស់ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៨/៦៩៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និង សាស្ត្រាចារ្យជំនួយ ដល់គ្រូនគរបាលជាតិ និង គ្រូបង្រៀន ក្នុងវិស័យសន្តិសុខជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

### សម្រេច

**ប្រការ១.**_

ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ រួមមាន **អាវ មួក** និង **រូបសញ្ញា** ដែលត្រូវបែងចែកជា ៣កម្រិត ដូចខាងក្រោម ៖

១. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យ។

២. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យរង។

៣. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យជំនួយ។

**ប្រការ២.**

ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ ប្រើប្រាស់ក្នុងពិធីទទួលឋានៈសាស្ត្រាចារ្យ ពិធីប្រគល់សញ្ញាបត្រ ពិធីវាយតម្លៃនិក្ខេបបទ វាយតម្លៃផ្តល់ឋានៈសាស្ត្រាចារ្យ និងវាយតម្លៃផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ក្នុងក្របខណ្ឌបណ្ឌិត្យសភានគរបាលកម្ពុជា។

**ប្រការ៣.**

ទម្រង់ កម្រិត លក្ខណៈ និងអត្ថន័យ នៃឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

**ប្រការ៤.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក និងប្រធានអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ២រោច ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ៧៥៩ ពក/ប្រក ចុះថ្ងៃ១២ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹងថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨
ស្តីពីការប្រើប្រាស់ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ

# ទម្រង់ឯកសណ្ឋាន សម្រាប់សាស្ត្រាចារ្យទាំងពាក់ម្រិត



# ទម្រង់ឯកសណ្ឋាន សម្រាប់សាស្ត្រាចារ្យ



# ទម្រង់ឯកសណ្ឋាន សម្រាប់សាស្ត្រាចារ្យរង



# ទម្រង់ឯកសណ្ឋាន សម្រាប់សាស្ត្រាចារ្យជំនួយ



# ទម្រង់មួក



ព្រះរាជសញ្ញា



ខណ្ឌទឹកមាស






រំយោល

## រូបសញ្ញា



**ឧបសម្ព័ន្ធ២** នៃប្រកាសលេខ ០៧៥៣៧ ប្រក ចុះថ្ងៃ ខ្នើ២ កោត ខែ ចន្តឹ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹងថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨
ស្តីពីការប្រើប្រាស់ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ

## កម្រិត លក្ខណៈ និងអត្ថន័យ
## នៃឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ

### I. កម្រិតឯកសណ្ឋាន

ឯកសណ្ឋានឋានៈសាស្ត្រាចារ្យក្នុងវិស័យសន្តិសុខជាតិ រួមមាន **អាវ មួក** និង **រូបសញ្ញា** ដែលត្រូវបែងចែកជា ៣កម្រិត ដូចខាងក្រោម ៖

១. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យ។

២. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យរង។

៣. ឯកសណ្ឋានសម្រាប់សាស្ត្រាចារ្យជំនួយ។

### II. លក្ខណៈឯកសណ្ឋាន

ឯកសណ្ឋានសម្រាប់ឋានៈសាស្ត្រាចារ្យ មានលក្ខណៈរួម និងមានលក្ខណៈដោយឡែក។

**១. លក្ខណៈរួម**

**១.១.អំពីអាវ**

ក. លក្ខណៈទូទៅ

- អាវមានពណ៌ខៀវខ្ចី ដែលលម្អដោយក្បាច់ភ្ញីទេស និងក្បាច់សន្លឹកភ្ញីទេស មានពណ៌មាស
- អាវមានទំហំធំ រលុង និងប៉ោង ហើយមានសម្រុងពីស្មារហូតដល់ត្រឹមពាក់កណ្តាលកំភួនជើង។

**ខ. ផ្នែកខាងមុខ**

- ផ្នែកអាវខាងមុខមានទម្រង់កបើក មានប៉ានពីមុខបន្ទះវែងពណ៌មាសលម្អដោយកម្រងក្បាច់ភ្ញីទេសចង្វាយ ចេញពីចំណុចប៉ូលស្មាទម្លាក់ពីលើចុះក្រោមមកដល់ចុងអាវ មានទទឹងប្រវែង៧សង់ទីម៉ែត្រម្ខាងៗ
- កម្រងក្បាច់ភ្ញីទេសនីមួយៗទាំងស្តាំទាំងឆ្វេង មានអមដោយខ្សែឆ្នូត៣ជួរ នៅទាំងពីរខាងក្បាច់សរុប ១២ជួរ
- នៅចន្លោះកម្រងក្បាច់ភ្ញីទេស រំលេចដោយក្រណាត់ពណ៌ខៀវចាស់
- អាវនីមួយៗមានឡេវពណ៌មាសចំនួន៥
- ឡេវក្រោមគេបំផុត មានកម្ពស់ស្មើនឹងពាក់កណ្តាលប៉ានចុងដៃពណ៌មាស នៃអាវទាំងពីរខាង។

**គ. ផ្នែកខាងក្រោយ**

ផ្នែកខាងក្រោយអាវ ពុំមានលម្អដោយក្បាច់អ្វីទាំងអស់ គ្រាន់តែមានជីបនៅផ្នែកខាងលើនៃកអាវ ដើម្បីឱ្យសម្រុងទម្លាក់ចុះក្រោមមានភាពធំទូលាយ។

**ឃ. ផ្នែកស្មា**

- ស្មាអាវមានជីបទាំងពីរខាង
- ស្មាអាវទាំងពីរខាង លម្អដោយក្បាច់សន្លឹកភ្ញីទេស ចំនួន៣ ចំនួន២ និងចំនួន១ នៅក្នុងស៊ុមរាងចតុកោណកែង ដែលមានគ្រែព័ទ្ធ៣ជុំ បណ្តោយប្រវែង១០សង់ទីម៉ែត្រ និងទទឹងប្រវែង៥សង់ទីម៉ែត្រ ព័ទ្ធជុំវិញសន្លឹកក្បាច់ភ្ញីទេស
- កម្រងក្បាច់នេះ បំពាក់លើស្មាទាំងពីរខាងតាមបណ្តោយសម្រុងដងខ្លួនមកផ្នែកខាងមុខ។

**ង. ផ្នែកដៃអាវ**

- អាវដៃវែងមានទំហំធំនិងរលុង ដែលត្រូវបានរចនាឱ្យសមនឹងតួអាវនិងដងខ្លួនរបស់សាមីខ្លួនម្នាក់ៗ
- ផ្នែកចំហៀងដៃអាវលម្អដោយក្បាច់សន្លឹកភ្ញីទេស ចំនួន៣ ចំនួន២ និងចំនួន១
- ផ្នែកចុងដៃអាវលម្អដោយកម្រងក្បាច់ភ្ញីទេសចង្វាយ និងអមម្ខាងៗដោយឆ្នូតចំនួន៣ជួរ មានទទឹងប្រវែង៨សង់ទីម៉ែត្រ។

## ១.២ អំពីមួក

- មួកមានទម្រង់ជាមួកសំបុក ប៉ោងរលុងខាងលើ មានវណ្ឌខាងក្រោម មានឆែកនិងរំយោលខាងក្រោយ
- មួកមានព្រះរាជសង្ហារពណ៌មាសនៅចំពីមុខ មានវណ្ឌពណ៌មាសនៅផ្នែកខាងក្រោម លម្អដោយសន្លឹកក្បាច់ភ្ញីទេសប្រដេញចំកណ្តាល មានទទឹងប្រវែង៤សង់ទីម៉ែត្រ
- ខាងក្រោយមួកមានឆែកពីក្រោយដែលមានជម្រៅ៤សង់ទីម៉ែត្រ
- មានរំយោលខ្សែសយពណ៌មាសមួយសសៃចងភ្ជាប់មួកចំកណ្តាលផ្នែកខាងក្រោម និងចងរឹតគល់ជុំរំយោលចេញជាជុំមូលនៅខាងលើកន្ទុយខ្សែសយមួយជុំ ដែលចងត្រម៉ោងគល់ មានទម្រង់ដូចគ្រាប់ឃ្លីមានអង្កត់ផ្ចិតប្រវែងប្រមាណ១,២សង់ទីម៉ែត្រ ដោយមានរំយោលសរសៃអំបោះពណ៌មាស មួយជុំទំហំ២សង់ទីម៉ែត្រ ធ្លាក់សំយ៉ុងចុះប្រវែង១៥សង់ទីម៉ែត្រ និង
- **មួកនេះមានលក្ខណៈរួម ប្រើបានសម្រាប់ឋានៈសាស្ត្រាចារ្យទាំង៣កម្រិត។**

## ១.៣.អំពីរូបសញ្ញា

រូបសញ្ញាឋានៈសាស្ត្រាចារ្យមានលក្ខណៈដូចខាងក្រោម ៖

- រូបសញ្ញាមានរាងជារង្វង់មូលពីរជាន់ ដែលរង្វង់ធំមានអង្កត់ផ្ចិតប្រវែង៣សង់ទីម៉ែត្រ និងរង្វង់តូចមានអង្កត់ផ្ចិតប្រវែង២សង់ទីម៉ែត្រ
- ចន្លោះរង្វង់ធំ និងរង្វង់តូច ត្រូវបានរចនាលម្អដោយក្បាច់គ្របកឈូកប្រដេញព័ទ្ធជុំវិញ
- កណ្តាលរង្វង់តូច ត្រូវបានរចនាលម្អដោយ «ក្បាច់ភ្ញីទេសចំនួន៣ទងសម្រាប់សាស្ត្រាចារ្យ» «២ទងសម្រាប់សាស្ត្រាចារ្យរង» និង «១ទងសម្រាប់សាស្ត្រាចារ្យជំនួយ»
- ផ្នែកខាងលើនៃរង្វង់តូចមានអក្សរចារឹកថា **«បណ្ឌិត្យសភានគរបាលកម្ពុជា»** ។ អក្សរចារឹកនេះអាចមានការផ្លាស់ប្តូរទៅតាមការប្តូរឈ្មោះអង្គភាព
- ផ្នែកខាងក្រោមនៃរង្វង់តូច ត្រូវបានរចនាដោយ «**ឫ**» ដែលមានអក្សរចារឹកថា **«សាស្ត្រាចារ្យ» «សាស្ត្រាចារ្យរង»** និង **«សាស្ត្រាចារ្យជំនួយ»**
- រូបសញ្ញាទាំងមូលមានពណ៌មាស
- រូបសញ្ញានេះប្រើប្រាស់ជាមួយឯកសណ្ឋានឋានៈសាស្ត្រាចារ្យ ឬឯកសណ្ឋានមន្ត្រីនគរបាលជាតិផ្សេងទៀត ឬឯកសណ្ឋានស៊ីវិល។

## ២.លក្ខណៈដោយឡែក

### ២.១. អាវគម្រិតសាស្ត្រាចារ្យ

- សក្តិលើស្មាមានសន្លឹកភ្ញីទេស៣ទង
- រំលេចក្បាច់សន្លឹកភ្ញីទេស៣ទង(៣ថ្នាក់)ស្ថិតនៅពាក់កណ្តាលដៃអាវ

### ២.២. អាវគម្រិតសាស្ត្រាចារ្យរង

- សក្តិលើស្មាមានសន្លឹកភ្ញីទេស២ទង
- រំលេចក្បាច់សន្លឹកភ្ញីទេស២ទង(២ថ្នាក់)ស្ថិតនៅពាក់កណ្តាលដៃអាវ។

### ២.៣. អាវគម្រិតសាស្ត្រាចារ្យជំនួយ

- សក្តិលើស្មាមានសន្លឹកភ្ញីទេស១ទង
- រំលេចក្បាច់សន្លឹកភ្ញីទេស១ទង(១ថ្នាក់)ស្ថិតនៅពាក់កណ្តាលដៃអាវ។

## III. អត្ថន័យឯកសណ្ឋាន

១. ឯកសណ្ឋានត្រូវបានរចនាឡើងតាមលក្ខណៈខ្មែរ ដោយយកក្បាច់ភ្ញីទេសពណ៌មាសមកប្រើសម្រាប់រចនាលម្អ។

- ពណ៌មាស ជាពណ៌ដែលតំណាងឱ្យភាពទៀងត្រង់ ថ្លៃថ្នូរ និង ឧត្តុង្គឧត្តម
- សន្លឹកក្បាច់ភ្ញីទេស តំណាងឱ្យវប្បធម៌ជាតិ លក្ខណៈសិល្បៈទន់ភ្លន់ និង ភាពរីកចម្រើនវិវឌ្ឍទៅមុខ គ្មានដែនកំណត់។

២. បន្ទាត់ឆ្នូតត្រង់ៗ តំណាងឱ្យភាពរឹងមាំ ប្រតិបត្តិបញ្ញត្តិដោយមិនលម្អៀង និងប្រកបដោយប្រសិទ្ធភាព។

៣. តួអាវទាំងមូល មានអត្ថន័យឆ្លុះបញ្ចាំងអំពីការអប់រំបណ្តុះបណ្តាលកម្រិតខ្ពស់ ពីព្រោះទម្រង់អាវបែបនេះ ត្រូវបានគេយកមកប្រើប្រាស់ជាសកលទាំងក្របខណ្ឌជាតិ ទាំងអន្តរជាតិ សម្រាប់សាស្ត្រាចារ្យ ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា និងនិស្សិតជ័យលាភី ពេលមានពិធីផ្លូវការនានា ទាក់ទងនឹងការទទួលសញ្ញាបត្រ ឬ គោរមងារផ្សេងៗ ក្នុងវិស័យអប់រំបណ្តុះបណ្តាល។

៤. មួកត្រូវបានរចនាឡើង ដោយផ្សារភ្ជាប់ទៅនឹងឯកសណ្ឋានកងកម្លាំងនគរបាលជាតិ ពីព្រោះទម្រង់មួកមានលក្ខណៈស្រដៀងទៅនឹងមួកប៉េរ៉េរបស់មន្ត្រីនគរបាលជាតិដែលប្រើប្រាស់បច្ចុប្បន្ន។

៥. ពណ៌ខៀវគឺជាពណ៌មួយក្នុងចំណោមពណ៌ទាំង៣ នៃពណ៌របស់ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ពណ៌ខៀវតំណាងឱ្យសុខសន្តិភាព និងការអភិវឌ្ឍ ដែលជាភារកិច្ចស្នូលរបស់កងកម្លាំងនគរបាលជាតិ ក្នុងការថែរក្សាសន្តិសុខ ជូនប្រជាពលរដ្ឋ និងសង្គមជាតិ។

៦. ក្បាច់សន្លឹកភ្ញីទេស ចំនួន៣ ចំនួន២ និងចំនួន១ ដែលលម្អផ្នែកចំហៀងដៃអាវ និងលម្អផ្នែកស្មាទាំងពីរខាង មានអត្ថន័យដូចខាងក្រោម៖

- ភ្ញីទេសចំនួន៣សន្លឹក សម្រាប់សាស្ត្រាចារ្យ
- ភ្ញីទេសចំនួន២សន្លឹក សម្រាប់សាស្ត្រាចារ្យរង
- ភ្ញីទេសចំនួន១សន្លឹក សម្រាប់សាស្ត្រាចារ្យជំនួយ

៧. រំយោលផ្នែកខាងក្រោយនៃមួក តំណាងឱ្យការអប់រំបណ្តុះបណ្តាលគ្មានទីបញ្ចប់។